ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ...១៥...សជណ

# សារលិខិត

## សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាស " ទិវាសេរីភាពសារព័ត៌មានសកលលោក " នាថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៨

អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ ជាទីស្រឡាញ់រាប់អាន

ថ្ងៃនេះ ខ្ញុំមានសេចក្ដីសោមនស្សរីករាយយ៉ាងក្រៃលែង តាងនាមរាជរដ្ឋាភិបាលកម្ពុជា និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ សូមសម្ដែងនូវការស្វាគមន៍យ៉ាងកក់ក្ដៅជាមួយបងប្អូនអ្នកសារព័ត៌មានជាតិ- អន្តរជាតិទាំងអស់ ដែលកំពុងបំពេញការងារលើវិស័យសារព័ត៌មាននៅក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា ក៏ដូចជានៅលើសកលលោកទាំងមូល ក្នុងឱកាសទិវាសេរីភាពសារព័ត៌មានសកលលោកដែលបានប្រារព្ធធ្វើឡើងនៅថ្ងៃទី០៣ ខែឧសភា ជារៀងរាល់ឆ្នាំ ក្នុងគោលបំណងលើកស្ទួយសេរីភាពនៃការបញ្ចេញមតិ សេរីភាពនៃសារព័ត៌មាន និងធានាបាននូវការផ្សព្វផ្សាយព័ត៌មានប្រកបដោយគុណភាព យុត្តិធម៌ និងការទទួលខុសត្រូវតាមវិជ្ជាជីវៈ ដើម្បីលើកស្ទួយតម្លៃសារព័ត៌មាន និងជំរុញឲ្យសារព័ត៌មានដើរតួនាទីកាន់តែសកម្ម និងមានសារសំខាន់ថែមទៀតនៅក្នុងសង្គមប្រជាធិបតេយ្យ និងជាដៃគូរបស់រាជរដ្ឋាភិបាលដែលមិនអាចខ្វះបាន។

ទិវាសេរីភាពសារព័ត៌មានសកលលោកឆ្នាំ២០១៨នេះ បានផ្ដោតលើប្រធានបទស្ដីពី " **ប្រព័ន្ធផ្សព្វផ្សាយយុត្តិធម៌ និងនីតិរដ្ឋ** " គឺពិតជាមានសារសំខាន់ស្របតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា ដែលចង់បានប្រព័ន្ធផ្សព្វផ្សាយមានថាមពល និងប្រកបដោយគុណភាព យុត្តិធម៌ និងការទទួលខុសត្រូវក្នុងការផ្ដល់ព័ត៌មានពិត ដែលជាកញ្ចក់ឆ្លុះបញ្ចាំងនូវភាពពិតជាក់ស្ដែងក្នុងសង្គម មិនឆ្វេងពេក មិនស្ដាំពេក គឺចលនាកណ្ដាលនិយម ដែលអាចទទួលយកបានទាំងអស់គ្នា ហើយសំខាន់បំផុតគឺហ៊ាននិយាយការពិត និងហ៊ានរិះគន់ក្នុងន័យស្ថាបនា ដើម្បីចូលរួមក្នុងការលើកស្ទួយលិទ្ធិប្រជាធិបតេយ្យ ការកសាងសង្គមមួយមានយុត្តិធម៌ នីតិរដ្ឋ សុខសន្តិភាព និងការអភិវឌ្ឍប្រកបដោយចីរភាព ដែលជាបំណងប្រាថ្នា និងជាចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា។

ក្នុងគោលដៅលើកស្ទួយសេរីភាពសារព័ត៌មាន និងនីតិរដ្ឋ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានគោរពយ៉ាងហ្មត់ចត់នូវគោលការណ៍សំខាន់ពីរគឺ សេរីភាពក្នុងការផ្សាយព័ត៌មានដោយគ្មានការត្រួតពិនិត្យជាមុន និងការផ្ដល់សិទ្ធិឲ្យជនបរទេសអាចធ្វើជាម្ចាស់ស្ថាប័នប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន។

សេរីភាពនេះត្រូវបានធានាដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ស្តីពីរបបសារព័ត៌មាន ដែលត្រូវបានគេមើលឃើញថា ជាប្រទេសដែលមានសេរីភាពខាងសារព័ត៌មានជាងប្រទេសដែលកាន់របបប្រជាធិបតេយ្យមួយចំនួននៅក្នុងតំបន់អាស៊ាន។

ការបើកទូលាយនូវសេរីភាពសារព័ត៌មាននៅកម្ពុជា បានធ្វើឲ្យវិស័យនេះមានការរីកចំរើនលូតលាស់យ៉ាងឆាប់រហ័ស និងសម្បូរបែប រាប់ទាំងសារព័ត៌មានបោះពុម្ពផ្សាយ សារព័ត៌មានអេឡិកត្រូនិក រួមមាន វិទ្យុ ទូរទស្សន៍ ទូរទស្សន៍ផ្កាយរណប និងទូរទស្សន៍គ្រប់ប្រភេទ ព្រមទាំងប្រព័ន្ធផ្សព្វផ្សាយតាមអនឡាញ ស្របតាមការវិវឌ្ឍនៃបច្ចេកវិទ្យាទំនើប និងសម្បូរបែបនាពេលបច្ចុប្បន្ន ហើយបានប្រែក្លាយប្រជាពលរដ្ឋម្នាក់ទៅជាម្ចាស់ប្រព័ន្ធផ្សព្វផ្សាយមួយដែលអាចផ្សព្វផ្សាយ និងចែករំលែកព័ត៌មានទៅទូទាំងសកលលោកបានយ៉ាងឆាប់រហ័សបំផុត។ បច្ចុប្បន្នមានអ្នកសារព័ត៌មានជាតិ និងអ្នកសារព័ត៌មានបរទេស ដែលកំពុងបំពេញបេសកកម្មដោយសេរីនៅក្នុងប្រទេសដ៏តូចមួយនេះ មានចំនួនជាងប្រាំមួយពាន់នាក់ បានចុះបញ្ជិកានៅក្រសួងព័ត៌មាន។

អ្នកសារព័ត៌មានជាតិ និងអន្តរជាតិជាទីស្រឡាញ់រាប់អាន

ធៀតក្នុងឱកាសដ៏វិសេសវិសាលនេះ ខ្ញុំសូមសម្តែងជូននូវការកោតសរសើរចំពោះអ្នកសារព័ត៌មានទាំងអស់ដែលបានខិតខំប្រឹងប្រែងបំពេញបេសកកម្មរបស់ខ្លួន ក្នុងការផ្សព្វផ្សាយ និងចែករំលែកព័ត៌មានជូនប្រជាជនបានដឹង និងស្វែងយល់អំពីព្រឹត្តិការណ៍ដែលកំពុងមាន ការប្រែប្រួលនៅទូទាំងសកលលោកតម្រូវឲ្យអ្នកសារព័ត៌មានធ្វើការឆ្លើយតបឲ្យបានទាន់ពេលវេលា ដើម្បីបំពេញសេចក្តីត្រូវការរបស់ប្រជាជនដែលបច្ចុប្បន្នព័ត៌មានបានក្លាយទៅជាចំណីអាហារដែលគេចង់ដឹង ចង់យល់អំពីសភាពការណ៍វិវឌ្ឍន៍ទាំងបញ្ហានយោបាយ សេដ្ឋកិច្ចសង្គម និងបញ្ហាដទៃទៀត ដែលពាក់ព័ន្ធនឹងជីវភាពប្រចាំថ្ងៃរបស់ពួកគេ។

ដើម្បីឲ្យប្រព័ន្ធផ្សព្វផ្សាយមានយុត្តិធម៌ និងប្រទេសមួយមាននីតិរដ្ឋ គឺទាមទារឲ្យអ្នកសារព័ត៌មានរបស់យើងខិតខំប្រឹងប្រែងបន្តទៀត នូវការអភិវឌ្ឍសមត្ថភាពយល់ដឹងរបស់ខ្លួន និងមានភាពស្មោះត្រង់ក្នុងវិជ្ជាជីវៈ ក្លាហានហ៊ាននិយាយការពិត និងដោយហ៊ានទទួលយកការពិត ដើម្បីឲ្យព័ត៌មានរបស់ខ្លួនក្លាយជាព័ត៌មានពិត ហើយធ្វើការឆ្លុះបញ្ចាំងឲ្យឃើញគ្រប់តថភាពសង្គម ដើម្បីចូលរួមប្រឆាំងអំពើពុករលួយ ការកែទម្រង់ច្បាប់ ប្រព័ន្ធយុត្តិធម៌ និងការកែទម្រង់រដ្ឋបាលសាធារណៈ ហើយការងាររបស់អ្នកកាសែតដែលត្រូវបំពេញមានច្រើនណាស់ទាំងនៅពេលបច្ចុប្បន្ន និងនៅពេលអនាគត។

នៅខែកក្កដាឆ្នាំ២០១៨ នាពេលដ៏ខ្លីខាងមុខនេះ កម្ពុជានឹងរៀបចំការបោះឆ្នោតសកលជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៦ តម្រូវឲ្យអ្នកសារព័ត៌មានប្រកាន់ភាពយុត្តិធម៌ ធ្វើការចូលរួមផ្សព្វផ្សាយនូវព័ត៌មានពិត ដើម្បីធានាឲ្យបរិយាកាសនយោបាយ និងដំណើរការនៃការបោះឆ្នោតបានប្រព្រឹត្តទៅប្រកបដោយភាពសេរី ត្រឹមត្រូវ និងយុត្តិធម៌ ហើយលទ្ធផលនៃការបោះឆ្នោតអាចទទួលយកបានគ្រប់ភាគីពាក់ព័ន្ធ ដែលឆ្លុះបញ្ចាំងពីឆន្ទៈពិតប្រាកដរបស់ប្រជាពលរដ្ឋដើម្បីធានាបាននូវសុខសន្តិភាពយូរអង្វែង និងសូមអ្នកសារព័ត៌មាន ជៀសវាងការតាំងខ្លួនជាចៅក្រមកាត់សេចក្តី ដែលជាការប្រព្រឹត្តខុសវិជ្ជាជីវៈរបស់ខ្លួន ដើម្បីកុំឲ្យកើតរឿងច្រំដែល។ អ្នកសារព័ត៌មានត្រូវស្តាប់គ្រប់សំឡេង និងត្រូវផ្តល់ជា

ទស្សនៈ ផ្តល់ជាគំនិត ដែលអ្នកដឹកនាំអាចយកទៅត្រិះរិះពិចារណា ដើម្បីយកទៅកែលម្អក្នុងក្របខណ្ឌគោលនយោបាយ ឬសកម្មភាពរបស់ខ្លួនៗ

ជាថ្មីម្តងទៀត ខ្ញុំសូមបងប្អូនអ្នកសារព័ត៌មានទាំងអស់ ជៀសវាងឲ្យបានការផ្សាយព័ត៌មានមិនពិត ការក្លែងព័ត៌មាន បន្ទុះបង្អាប់នាំឲ្យមានការស្អប់គុំកួន ការញុះញង់អុជអាលឲ្យមានការប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ជំនឿ សាសនា និន្នាការនយោបាយ និងការផ្សព្វផ្សាយព័ត៌មានដែលបង្កឲ្យកើតមានអវិភាពដល់ទំនាក់ទំនងជាមួយប្រទេសដទៃ ដែលបង្កប់ទៅដោយចេតនាទុច្ចរិតក្នុងគោលដៅបង្កចលាចលក្នុងសង្គមធ្វើឲ្យប៉ះពាល់សណ្តាប់ធ្នាប់សាធារណៈ ដែលទង្វើទាំងនេះជាអំពើល្មើសរបស់អ្នកសារព័ត៌មានដែលគ្មានវិជ្ជាជីវៈ គ្មានការទទួលខុសត្រូវ បង្កើតជាបញ្ហា បង្កឲ្យមានការបែកបាក់ជាតិសាសន៍ និងមានសង្គ្រាមជាមួយបរទេសបង្កឲ្យអន្តរាយដល់ប្រទេសជាតិៗ ការជេរប្រមាថ ការញុះញង់ឲ្យកើតមានជម្លោះជាតិសាសន៍ ឬជម្លោះប្រដាប់អាវុធបង្កសង្គ្រាមនោះ មិនមែនជាវិជ្ជាជីវៈរបស់អ្នកសារព័ត៌មានទេ ហើយក៏មិនមែនជាដំណើរការនៃលទ្ធិប្រជាធិបតេយ្យដែរៗ

មុននឹងបញ្ចប់ ខ្ញុំសូមអំពាវនាវដល់អ្នកសារព័ត៌មានជាតិ និងអ្នកសារព័ត៌មានបរទេសទាំងអស់ ដែលកំពុងបំពេញការងារនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងបំពេញការងារនៅបរទេសក្តី សូមយកចិត្តទុកដាក់អនុវត្តឲ្យបានត្រឹមត្រូវតាមក្រមសីលធម៌ វិជ្ជាជីវៈ ជៀសវាងការផ្សព្វផ្សាយព័ត៌មានតែមួយជ្រុង ហើយធ្លុះបញ្ចាំងសភាពការណ៍ទាំងមូល ដោយពុំបានគិតអំពីក្បួនខ្នាតក្រឹត្យក្រមនៃការសរសេរព័ត៌មាន ឬការផ្សព្វផ្សាយព័ត៌មានមិនពិត បំប៉ោងសភាពការណ៍ ដោយគិតតែអំពីផលប្រយោជន៍ផ្ទាល់ខ្លួនធ្វើឲ្យបាត់បង់តម្លៃសារព័ត៌មានខ្លួនឯង និងខិតខំអភិវឌ្ឍឲ្យមានការយល់ដឹងខ្ពស់ មានសមត្ថភាពក្នុងការវិភាគសភាពការណ៍ទាំងព្រឹត្តិការណ៍ជាតិ និងអន្តរជាតិដើម្បីដើរទាន់ការវិវឌ្ឍសភាពការណ៍សកលលោកៗ

ទីបញ្ចប់ ខ្ញុំសូមជូនពរបងប្អូនអ្នកសារព័ត៌មានជាតិ និងអន្តរជាតិទទួលជោគជ័យក្នុងការបំពេញតួនាទីភារកិច្ចរបស់ខ្លួន និងសូមប្រកបនឹងពុទ្ធពរទាំង៥ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ បដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយៗ

ថ្ងៃពុធ៣ រោច ខែពិសាខ ឆ្នាំច សំរឹទ្ធស័ក ព.ស. ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**